# សេចក្តីព្រាង
# ច្បាប់ស្តីអំពីការបង្កើតនិងការប្រព្រឹត្តិទៅ
# នៃគណៈកម្មការបង្ការទារុណកម្ម

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

មាត្រា១: គោលបំណងនៃច្បាប់នេះ

ច្បាប់នេះមានគោលបំណងបង្កើតនិងកំណត់ការប្រព្រឹត្តិនៃគណៈកម្មការមួយដែលមានឈ្មោះថា "គណៈកម្មការបង្ការទារុណកម្ម"ដែលហៅកាត់ថា "គបទ" ដោយអនុលោមតាមពិធីសារបន្ថែមលើ អនុសញ្ញានៃអង្គការសហប្រជាជាតិប្រឆាំងទារុណកម្មនិងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែល ហៅកាត់ថា «ពបអបទ» ដែលព្រះរាជាណាចក្រកម្ពុជាបានឲយសច្ចាប័ននៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ហើយចូលជាធរមាននៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៧ ។

មាត្រា ២: **លំដាប់ឋានានុក្រម និងសិទ្ធិអំណាចរបស់ គបទ**

គបទ មានសិទ្ធិអំណាចចេញចូលពិនិត្យរាល់ទីកន្លែងឃុំឃាំងជនដែលត្រូវបានដកហូតសេរីភាពទូទាំងព្រះរាជាណាចក្រ ដើម្បីត្រួតពិនិត្យមើលលក្ខ័ណ្ឌនៃការប្រព្រឹត្តទៅលើជនទាំងឡាយដែលត្រូវបានដកសេរីភាពរបស់ខ្លួន ក្នុងគោលបំណងបង្ការទារុណកម្មនិងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងធ្វើឲយមានការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនទាំងនោះ ។

គបទ ជាអាជ្ញាធរឯករាជ ។ អាជ្ញាធរនេះមិនត្រូវទទួលបទបញ្ជាពីអាជ្ញាធរណាមួយឯទៀតឡើយក្នុងការប្រើប្រាស់អំណាច និងក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដែលមានកំណត់ក្នុងច្បាប់នេះ ។

គបទ បំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ និងទៅតាមការណែនាំនៃគោលការណ៍ដែលមានចែងក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិនេះ ជាពិសេស អនុសញ្ញានៃអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម ដែលហៅកាត់ថា "អសប-អបទ" និង "ពបអបទ" ព្រមទាំងនិយាមនិងស្តង់ដារបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។

ក្នុងការប្រើប្រាស់សិទ្ធិអំណាច និងការបំពេញកាតព្វកិច្ចរបស់ខ្លួន គបទ ត្រូវគោរពដែនសមត្ថកិច្ចរបស់អំណាចតុលាការទៅលើ ជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។

## មាត្រា ៣: និយមន័យ និងគោលការណ៍ណែនាំ

ដើម្បីគោលបំណងនៃច្បាប់នេះ និយមន័យ "ទារុណកម្ម" ដែលមានកំណត់ក្នុងមាត្រា ១ នៃ អសប-អបទ ត្រូវយកមកអនុវត្ត ។ មាត្រា១នេះចែងថា:

ពាក្យ "ទារុណកម្ម" មានន័យថា អំពើទាំងឡាយណាដែលនាំឲយមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយ ដូចជា ទាញយកពត៌មានពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុណាផ្សេងទៀត ដែលផ្អែកលើការ

រើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខបង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ ។ ពាក្យ "ទារុណកម្ម" មិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខ ដែលកើតឡើងជាប់ឬម្តងម្កាល ពីទារុណកម្មតាមច្បាប់ឡើយ ។

ដើម្បីគោលបំណងនៃច្បាប់នេះ និយមន័យ "អំពើឃោឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប" ដែលមាត្រា ១៦ នៃ អសប-អបទ បាននិយាយដល់ និងដែលកំណត់ដោយស្ថាប័នមានអំណាចឥទ្ធិពលអន្តរជាតិរួមមាន តែមិនកម្រិតត្រឹម គណៈកម្មការអង្គារសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស និងក្រុមប្រឹក្សាអង្គារសហប្រជាជាតិស្តីពីសិទ្ធិមនុស្សដែលជាស្ថាប័នជំនួសគណៈកម្មការនេះ គណៈកម្មាធិការប្រឆាំងទារុណកម្ម និងគណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស ត្រូវយកមកអនុវត្ត ។ គបទ ត្រូវផ្សាយជាសាធារណៈនូវនិយមន័យដែលខ្លួនប្រើប្រាស់ ហើយជម្រាបនិយមន័យទាំងនោះទៅរាល់អាជ្ញាធរពាក់ព័ន្ធទាំងអស់ឲយបានដឹង ។

ដើម្បីគោលបំណងនៃច្បាប់នេះ "ការដកហូតសេរីភាព" មានន័យថាការឃុំឃាំង ឬការដាក់ព័ន្ធនាគារ ឬការដាក់ជនណាម្នាក់នៅក្នុងកន្លែងឃាត់ខ្លួនសាធារណៈឬឯកជន ដែលជននោះមិនត្រូវបានឲយចេញតាមចិត្តដោយការបញ្ជាពីអាជ្ញាធរតុលាការ រដ្ឋបាល ឬអាជ្ញាធរដ៏ទៃទៀត ។

ទីកន្លែងដែលមានការដកហូតសេរីភាពរួមមាន តែមិនកម្រិតត្រឹមទីកន្លែងដូចតទៅនេះទេ:

» ពន្ធនាគារ

» អង្គភាពនគរបាលយុត្តិធម៌

» បន្ទប់ឃុំឃាំងរបស់តុលាការ

» មន្ទីរពេទ្យសាធារណៈឬឯកជន

» មជ្ឈមណ្ឌលព្យាបាលជម្ងឺសរសៃប្រសាទ

» មជ្ឈមណ្ឌលសម្បទា

» មជ្ឈមណ្ឌលឃុំឃាំងយុវជន

» លំនៅឋានដែលគេបញ្ជាឲយមនុស្សរស់នៅតែមិនឲយចេញ

» មជ្ឈមណ្ឌលឃុំឃាំងជនភៀសខ្លួន

» មជ្ឈមណ្ឌលឃុំឃាំងជនអន្តោប្រវេស

» ជំរុំយោធា ឬទីកន្លែងឃុំឃាំងក្រោមការត្រួតត្រារបស់យោធា

» មជ្ឈមណ្ឌលនគរបាលព្រំដែន និងមជ្ឈមណ្ឌលដំបន់ឆ្លងកាត់ឯទៀត

» យានយន្តដឹកជញ្ជូនជនដែលត្រូវបានដកហូតសេរីភាព ។

គបទ និងអាជ្ញាធរសាធារណៈពាក់ព័ន្ធត្រូវសហការគ្នាដើម្បីកំណត់ទីកន្លែងដែលមានការដកហូតសេរីភាព ហើយដែលត្រូវដាក់ឲយស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ គបទ ដូចដែលមានកំណត់នៅក្នុងច្បាប់នេះ ។

## ជំពូកទី២
## ការបង្កើត គបទ

### មាត្រា៩: សមាសភាព ការតែងតាំង និង អាណត្តិ

គបទ មានប្រធានមួយរូបដឹកនាំដោយមានជំនួយពីអនុប្រធានមួយរូប និងប្រតិភូយ៉ាងច្រើនបំផុត៩រូប ។ ប្រធាននិងអនុប្រធានត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមការស្នើសុំរួមគ្នាពីគណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋសភានិងព្រឹទ្ធសភា ។

ប្រធាន អនុប្រធាន និងប្រតិភូមានអាណត្តិ៦ឆ្នាំ ហើយមិនអាចត្រូវបានតែងតាំងជាថ្មីទៀតបានឡើយ ។អាណត្តិនេះមិនត្រូវបានបញ្ចប់មុនបានទេ លើកលែងតែមានការសុំលាលែង ឬអសមត្ថភាព ។

ប្រធានតែងតាំងប្រតិភូ ។ ប្រធានកំណត់ការទទួលខុសត្រូវរបស់ប្រតិភូ ដោយមានការពិគ្រោះជាមួយអនុប្រធានជាមុនសិន ។ ប្រតិភូស្ថិតនៅក្រោមការត្រួតផ្ទាល់របស់ប្រធាន ។

ប្រតិភូត្រូវបានតែងតាំងរយៈការពិគ្រោះជាមុនជាមួយគណៈកម្មាធិការមួយដែលមានតំណាងសង្គមស៊ីវិល ស្ថាប័នជាតិការពារសិទ្ធិមនុស្ស អង្គការសមាគមវិជ្ជាជីវៈ និងសាកលវិទ្យាល័យ ជាសមាជិក ។

ប្រធាន អនុប្រធាន
និងប្រតិភូត្រូវតែជាមនុស្សដែលមានសីលធម៌ខ្ពស់ និងបទពិសោធន៍ក្នុងវិជ្ជាជីវៈជាសាក្ខីភាពក្នុងវិស័យការគ្រប់គ្រងយុត្តិធម៌ ជាពិសេសវិស័យច្បាប់ព្រហ្មទណ្ឌ ការគ្រ់គ្រងពន្ធនាគារ ឬនគរបាល ពេទ្យទូទៅ ពេទ្យសរសៃប្រសាត ឬការការពារសិទ្ធមនុស្ស ។

## មាត្រា ៥: ឯករាជភាព

ប្រធាន អនុប្រធាន និងប្រតិភូផ្ទាល់ខ្លួនត្រូវតែជាបុគ្គលឯករាជពីអាជ្ញាធររដ្ឋនានា មិនកាន់មុខតំណែងឯទៀតណាមួយតាមរយៈការបោះឆ្នោតឬការតែងតាំង និងគ្មានសកម្មភាពវិជ្ជាជីវៈនិងការចូលរួមនយោបាយណាឡើយ ។ នៅពេលបានទទួលការតែងតាំងនិងមុនចូលកាន់មុខតំណែងក្នុង គបទ អ្នកទាំងនេះត្រូវបញ្ឈប់មុខការទាំងអស់ដែលខ្លួនមាន ។ សមាជិក គបទ ទាំងនេះមិនត្រូវហាមឃាត់មិនឲយបង្រៀន ឬចូលរួមក្នុងសកម្មភាពវប្បធម៌ សង្គមកិច្ច ឬមនុស្សធម៌ឡើយ ។

## មាត្រា៦: អភ័យឯសិទ្ធ

ប្រធាន អនុប្រធាន ប្រតិភូនិងអ្នកជំនាញការមិនត្រូវបានចាប់ ឃុំឃាំង ឬជាប់ចោទពីបទព្រហ្មទណ្ឌ ឬរដ្ឋបវេណីដោយមកពីមតិដែល

ខ្លួនបានបញ្ចេញ ឬទង្វើដែលខ្លួនបានធ្វើក្នុងការបំពេញមុខការរបស់ខ្លួនឡើយ ។

## មាត្រា ៧: បទបញ្ជាផ្ទៃក្នុង

ប្រធានចេញបទបញ្ញត្តិនានាកំណត់បទបញ្ជាផ្ទៃក្នុងសំរាប់ការប្រព្រឹត្តទៅរបស់ គបទ ក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធាននិងប្រតិភូដែលបានតែងតាំងរួចហើយ ។ បទបញ្ជាផ្ទៃក្នុងទាំងនេះរួមមាន តែមិនកម្រិតតែត្រឹម:

ក) ការគ្រប់គ្រងទូទៅ ការគ្រប់គ្រងហិរញ្ញវត្ថុ

(ខ) រចនាសម្ព័ន្ធនិងបញ្ញត្តិស្តីពីដំណើរការប្រព្រឹត្តទៅ នីតិវិធីបណ្តឹងតវ៉ា

(គ) ការជ្រើសរើស ការតែងតាំង លក្ខ័ណ្ឌការងារ ការទទួលខុសត្រូវ បុពសិទ្ធនិងសិទ្ធិ ប្រាក់បៀវត្ស អត្រាការវាយតម្លៃការងារ ការតម្លើងឋានន្តរស័ក្តិ និងវិន័យរបស់បុគ្គលិក

(ឃ) ការកំណត់មុខការសំរាប់អ្នកជំនាញការ ហើយនិង

(ង) ប្រាក់បំណាច់សំរាប់ជំនាញការនិងការផ្តល់គំនិតប្រឹក្សា ។

ប្រធានត្រូវធ្វើតាមនីតិវិធីដដែលដើម្បីអនុម័តក្រមសីលធម៌មួយសំរាប់បុគ្គលិកនិងអ្នកជំនាញការក្នុងការបំពេញមុខការរបស់ខ្លួន ។

ប្រធានមានការទទួលខុសត្រូវក្នុងការតែងតាំងបុគ្គលិក គបទ ឯទៀត ហើយបើការងារ គបទ តម្រូវ ក្នុងការជ្រើសរើសនិងប្រគល់បេសកកម្មដល់អ្នកជំនាញការឯករាជ ដែលត្រូវបានជ្រើសរើសក្នុងចំណោមមនុស្សដែលមានសីលធម៌ខ្ពស់និងមបទពិសោធន៍ក្នុងវិជ្ជាជីវៈជាសាក្ខីភាពក្នុងវិស័យការគ្រប់គ្រងយុត្តិធម៌ ជាពិសេសវិស័យច្បាប់ព្រហ្មទណ្ឌ ការគ្រប់គ្រងពន្ធនាការឬនគរបាល ពេទ្យទូទៅ ពេទ្យសរសៃប្រសាត ឬការការពារសិទ្ធមនុស្ស ។

ក្នុងការជ្រើសរើសនិងការតែងតាំងបុគ្គលិកនិងអ្នកជំនាញការ ប្រធានត្រូវយកចិត្តទុកដាក់ឲយមានតុល្យភាពរវាងភេទ និងពូជសាសន៍ ជនជាតិភាគតិច និងតំបន់ភូមិសាស្ត្រផ្សេងៗគ្នា ។

ដើម្បីគោលបំណងនៃច្បាប់នេះ បុគ្គលិក គបទ គឺរួមមានប្រធាន អនុប្រធាន និងប្រតិភូ នយោជិតនិងអ្នកជំនាញការដែលប្រធានតែងតាំង ។

**មាត្រា ៨:** លេខាធិការដ្ឋាន

គបទ ត្រូវមានលេខាធិការដ្ឋានមួយដើម្បីជួយកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ ។

ប្រធានតែងតាំងមន្ត្រីរដ្ឋបាលម្នាក់សំរាប់គ្រប់គ្រងលេខាធិការដ្ឋាន ។ មន្ត្រីរដ្ឋបាលនេះទទួលខុសត្រូវចំពោះប្រធាន ឬចំពោះអនុប្រធាន បើសិនជាប្រធានធ្វើប្រតិភូកម្មឲយអនុប្រធាន ។

មាត្រា ៩: ការទទួលខុសត្រូវ និងភារៈកិច្ចរបស់បុគ្គលិកនិងអ្នកជំនាញការ

បុគ្គលិកនិងអ្នកជំនាញការទាំងអស់ទទួលខុសត្រូវចំពោះមុខប្រធាន ។ អ្នកជំនាញការទទួលបទបញ្ជានិងាការណែនាំពីប្រធានតែប៉ុណ្ណោះ លើកលែងតែពីអនុប្រធាន ឬប្រតិភូដែលបានទទួលប្រតិភូកម្មសិទ្ធិ អំណាចពីប្រធាន ។ បុគ្គលិកនិងអ្នកជំនាញការទាំងអស់ត្រូវចូលរួមតាក់តែងគោលនយោបាយទូទៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ គបទ ។

តាមការបង្គាប់បញ្ជារបស់ប្រធាន បុគ្គលិកនិងអ្នកជំនាញការត្រូវផ្តល់ជូននូវពត៌មាន និងជំនួយការបច្ចេកទេស ទាំងអស់នេះដែលចាំបាច់សម្រាប់ធ្វើឲយការបំពេញបេសកកម្មបានប្រកបដោយជោគជ័យ ។ ពួកគេត្រូវក្នុងការរៀបចំការទៅពិនិត្យមើលទីកន្លែងដែលមានការដកហូតសេរីភាព និងធ្វើការសម្ភាសជាមួយជនទាំងឡាយដែលជាប់ឃុំឃាំងនៅ

ទីនោះ តាមសេចក្តីសម្រេចចិត្តរបស់ប្រធាន ហើយត្រូវដាក់របាយការណ៍ និងអនុសាសន៍ជូនប្រធានបន្ទាប់ពីបានបញ្ចប់បេសកកម្ម ។

ប្រធានមានសិទ្ធិទៅពិនិត្យមើលទីកន្លែងដែលមានការដកហូតសេរីភាព និង-ឬចាត់អនុប្រធាន ប្រតិភូ បុគ្គលិក និង-ឬអ្នកជំនាញការ ឲយទៅជាមួយ ឬឲយទៅពិនិត្យមើលដោយមិនបាច់មានប្រធាន ឬបំពេញភារៈកិច្ចផ្សេងទៀតដោយខ្លួនឯង ជាបុគ្គលម្នាក់ៗឬជាក្រុម ។ អនុប្រធាន ឬប្រតិភូណាម្នាក់ធ្វើការពិនិត្យមើលដូចគ្នានេះបានដែរក្រោយដែលបានជម្រាបប្រធានហើយ ។

គបទ ត្រូវទទួលរ៉ាប់រងចំណាយទាំងអស់ទៅលើរាល់ការពិនិត្យមើល និងរាល់ការបំពេញភារៈកិច្ចទាំងនោះ។

គបទ ត្រូវរៀបចំឲយមានបញ្ជីអ្នកជំនាញការក្នុវិស័យពាក់ព័ន្ធ ហើយសើរើបញ្ជីឲយទាន់បច្ចុប្បន្នភាពជារឿយៗ ។

មាត្រា ១០: ការសម្ងាត់ ក្នុងវិជ្ជាជីវៈ

ប្រធាន អនុប្រធាន ប្រតិភូ បុគ្គលិក និងអ្នកជំនាញការដែលបំរើការឲយ គបទ ត្រូវរក្សាការសម្ងាត់ក្នុងវិជ្ជាជីវៈ ចំពោះហេតុការណ៍ ទង្វើ និងពត៌មានដែលខ្លួនបានដឹងក្នុងការបំពេញមុខនាទីរបស់ខ្លួន លើកលែងតែចំពោះហេតុការណ៍ ទង្វើ និងពត៌មានដែលចាំបាច់សម្រាប់ធ្វើរបាយការណ៍ បញ្ចេញមតិ និងធ្វើអនុសាសន៍ ។

គបទ មិនត្រូវសរសេរក្នុងរបាយការណ៍ផ្សាយនូវពត៌មានណាដែលអាចបង្ហាញអត្តសញ្ញាណរបស់ជនណាមួយដែលស្ថិតនៅក្នុងក្របខ័ណ្ឌការសម្ងាត់ក្នុងវិជ្ជាជីវៈឡើយ ។ ពត៌មានផ្ទាល់ខ្លួនរបស់ជនណាម្នាក់មិនអាចត្រូវបានបង្ហាញឲយគេដឹងឡើយ បើគ្មានការយល់ព្រមពីជនពាក់ព័ន្ធនោះទេ ។

មាត្រា ១១: ថវិកា

គបទត្រូវមានត្រូវមានធនធានចាំបាច់ទាំងអស់សម្រាប់ការប្រព្រឹត្តទៅដោយប្រសិទ្ធិភាពរបស់ខ្លួន ។គបទ ត្រូវមានថវិកាស្វ័យតដែលខ្លួនមានភារៈកិច្ចរៀបចំដោយផ្ទាល់ ។ ថវិកានេះត្រូវបញ្ចូលជាផ្នែកមួយនៃថវិកាជាតិដែលសភាអនុម័ត ។

គបទ អាចទទួលអំណោយពីប្រភពនានាទាំងអស់បាន ។

ប្រធានជាអ្នកទទួលខុសត្រូវចំពោះការគ្រប់គ្រងថវិកាដោយអនុលោមតាមបទបញ្ញត្តិហិរញ្ញវត្ថុសាធារណៈ ។ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ប្រធាននេះមិនត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យជាដំបូងពីក្រសួងហិរញ្ញវត្ថុនិងសេដ្ឋកិច្ចឡើយ ។ គនៈនេយ្យរបស់ គបទ ត្រូវបានធ្វើសវនកម្មជាក្រោយដោយមន្ទីរសវនកម្មជាតិតែប៉ុណ្ណោះ ។

គបទ ត្រូវមានទីតាំងខ្លួនឯងមួយ ដាច់ដោយឡែកពីអាគាររដ្ឋាភិបាល ឬសភា ។

## ជំពូកទី ៣
## សមត្ថកិច្ច ការធានាការពារ និងអំណាចរបស់ គបទ

### មាត្រា ១២: សិទ្ធិអំណាចទូទៅ

ដោយអនុលោមតាមមាត្រា ១៩ នៃ ពបអបទ គបទ ត្រូវមានសិទ្ធិអំណាចដូខាងក្រោមៈ

(ក) ពិនិត្យយ៉ាងទៀងទាត់ អំពីការប្រព្រឹត្តទៅលើជនដែលត្រូវបានដកហូតសេរីភាព នៅក្នុងទីកន្លែងឃុំឃាំងទាំងឡាយដូចមានកំណត់ក្នុងមាត្រា ៤ នៃ ពបអបទ និងមានរៀបរាប់ក្នុងមាត្រា ៣ នៃច្បាប់នេះ ក្នុងគោលដៅពង្រឹង ប្រសិនជាចាំបាច់ នូវការការពារប្រឆាំងនឹងទារុណកម្ម

និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

(ខ) ផ្តល់អនុសាសន៍ដល់អាជ្ញាធរពាក់ព័ន្ធ និងជួយអាជ្ញាធរទាំងឡាយនេះឲយគិតគូរអំពីតម្រូវការនិងមធ្យោបាយចាំបាច់ សម្រាប់ការការពារជនដែលត្រូវបានដកហូតសេរីភាព និងបង្ការកុំឲយមានទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

(គ) ដាក់សេចក្តីសង្កេតនិងអនុសាសន៍ជូនអាជ្ញាធរពាក់ព័ន្ធសម្រាប់ធ្វើវិសោធនកម្មច្បាប់ ឬបទបញ្ញត្តិជាធរមាន ឬនិម៍តច្បាប់ ឬបទបញ្ញត្តិថ្មីទៅតាមករណី

ដើម្បីកែលំអលក្ខណៈការឃុំឃាំងជនដែលត្រូវបានដកហូតសេរីភាព

(ឃ) សហការជាមួយអង្គការនិងយន្តការនានារបស់អង្គការសហប្រជាជាតិ ព្រមទាំងស្ថាប័នឬអង្គការជាតិ ប្រចាំតំបន់ ឬអន្តរជាតិ នានាដែលធ្វើការងារដើម្បីពង្រឹងការពារមនុស្សទាំងអស់ ប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

(ង) ចាប់អារម្មណ៍ជាពិសេសទៅលើក្រុមដែលងាយទទួលរងគ្រោះ ដូចជាស្ត្រី កុមារ ជនអន្តោប្រវេស មនុស្សមានជម្ងឺរាងកាយ ឬជម្ងឺសរសៃប្រសាត និងមនុស្សចាស់ ។

## មាត្រា ១៣: សិទ្ធិចេញចូលទីកន្លែងឃុំឃាំង

គបទ ត្រូវមានសិទ្ធិចេញចូលទីកន្លែងដែលមានការដកហូតសេរីភាព និងមានសេរីភាពក្នុងការជ្រើសរើសទីកន្លែងដែល ចង់ទៅពិនិត្យមើល ក្នុងការជ្រើសរើសជនដែលចង់សម្ភាស និងក្នុងការជ្រើសរើសពេលវេលានិងទីកន្លែងសម្រាប់ការសម្ភាសជនទាំងនេះ ។

ដោយអនុលោមតាមមាត្រា ២០ នៃ ពបអបទ អាជ្ញាធរសាធារណៈ និងភ្នាក់ងាររបស់គេត្រូវរ៉ាប់រងជួយសម្រួលការងាររបស់ គបទ ។ ពួកគេត្រូវរ៉ាប់រងផ្តល់ គបទ នូវសិទ្ធិចេញចូលរាល់ទីកន្លែងឃុំឃាំង និងការរៀបចំទីតាំងនិងមធ្យោបាយជួយសម្រួលនានាដែលរួមមានតែមិនក្រិតត្រឹមតែៈ ទីស្នាក់នៅ បន្ទប់ឃុំដាច់ដោយឡែកចោលម្នាក់ឯង ទីធ្លាហាត់ប្រាណ រោងធ្វើម្ហូបអាហារ រោងជាង ទីកន្លែងនិងមធ្យោបាយផ្តល់ការអប់រំ ទីកន្លែងនិងមធ្យោបាយព្យាបាលជម្ងឺ ទីតាំងបន្ទប់ទឹកបង្គន់អនាម័យ និងលំនៅដ្ឋានបុគ្គលិក ។

## មាត្រា ១៤: សិទ្ធិទទួលពត៌មាន

ជនរងគ្រោះ សាក្សី និង ជនដែលជាប់សង្ស័យថាបានធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវចូលរួមជួយនិងសហការជាមួយ គបទ ក្នុងការស៊ើបអង្កេតរបស់គេ ។ គបទ អាចសុំទៅតុលាការឲយចេញដីកាបង្គាប់ឲយចូលខ្លួន ដើម្បីធានាការចូលរួមជួយនិងសហការនេះ ។

ដោយអនុលោមតាមមាត្រា ២០ នៃ ពបអបទ អាជ្ញាធរសាធារណៈ និងភ្នាក់ងាររបស់គេត្រូវរ៉ាប់រងជួយសម្រួលការងាររបស់ គបទ ។ ពួកគេត្រូវសហការជាមួយ គបទ និងផ្តល់ដល់ គបទ នូវពត៌មានទាំងដែល គបទ ត្រូវការ ។ ពួកគេត្រូវរ៉ាប់រងផ្តល់ជូន គបទ នូវៈ

(ក) សិទ្ធិទទួលពត៌មានទាំងអស់អំពីចំនួនជនដែលត្រូវបានដកហូតសេរីភាពនៅតាមទីកន្លែងឃុំឃាំងទាំងឡាយដូចមានចែងក្នុងមាត្រា ៤ នៃ ពបអបទ និងមាត្រា ៣ នៃច្បាប់នេះ ព្រមទាំងចំនួនទីកន្លែងឃុំឃាំងនិងទីតាំងនៃទីកន្លែងទាំងនេះ

(ខ) សិទ្ធិទទួលពត៌មានអំពីការប្រព្រឹត្តទៅលើជនទាំងនោះ ព្រមទាំងលក្ខណៈនៃការឃុំឃាំងជនទាំងនោះ

(គ) សិទ្ធិប្រស្រ័យទាក់ទងផ្ទាល់ជាមួយអនុគណៈកម្មាធិការបង្ការ បញ្ជូនពត៌មានទៅឲយគេ សុំគំនិតប្រឹក្សាពីគេ និងជួបជាមួយគេ ។

លក្ខណៈសម្ងាត់នៃពត៌មាននិងឯកសារពុំអាចយកទៅរាំងសិទ្ធិទទួលពត៌មានរបស់ គបទ បានឡើយ ។

## ជំពូកទី ៤
## ការពិនិត្យរបស់ គបទ

### មាត្រា ១៥: ការពិនិត្យកន្លែងឃុំឃាំង

គបទ ត្រូវរ៉ាប់រងធ្វើការពិនិត្យមើលជាទៀងទាត់និងមិនឲយដឹងជាមុន នូវទីកនលែងដែលមានការដកហូតសេរីភាពដែលមានចែងក្នុងមាត្រា ៤ នៃ ពបអបទ និងមាត្រា ៣ នៃច្បាប់នេះ ។

គបទ ត្រូវធ្វើផែនការនៃការពិនិត្យមើលទៀងទាត់នូវទីកន្លែងដែលមានការដកហូតសេរីភាព និងយ៉ាងហោចណាស់ត្រូវធ្វើការពិនិត្យមើលទីកន្លែងនិមួយៗនោះបានមួយដងក្នុងមួយឆ្នាំ ។ គបទ អាចធ្វើការពិនិត្យមើលចំពោះកិច្ចបើកាលៈទេសៈទាមទារឲយមានការធ្វើការពិនិត្យមើលបែបនេះ ។

គបទ ត្រូវអាចធ្វើសម្ភាសជាឯកជនស្ងាត់ជាមួយជនដែលត្រូវបានដកហូតសេរីភាពដោយគ្មានសាក្សី ជាផ្ទាល់ខ្លួនក្តី ឬដោយមានអ្នកបកប្រែ បើចាំបាច់ក្តី ព្រមទាំងជាមួយជនណាដែល គបទ យល់ថាអាចជួយផ្តល់ជំនួយបច្ចេកទេសបាន ។

### មាត្រា ១៦: ការជម្ទាស់ទៅនឹងការពិនិត្យមើល

ការជម្ទាស់ទៅនឹងការពិនិត្យទីកន្លែងឃុំឃាំងណាមួយ អាចធ្វើទៅបានលុះណាតែមានមូលហេតុសុវត្ថិភាពសាធារណៈ គ្រោះមហន្តរាយ

ធម្មជាតិ ឬក៏ការបះបោរទប់មិនឈ្នះនៅទីកន្លែឃុំឃាំងដែលត្រូវពិនិត្យមើលតែប៉ុណ្ណោះ ។ ប្រធានទីកន្លែងពាក់ព័ន្ធ ដោយមានការអនុម័តយល់ព្រមពីរដ្ឋមន្ត្រីពាក់ព័ន្ធផង ត្រូវជូនដំណឹងអំពីមូលហេតុនេះទាំងឡាយនេះជាលាយលក្ខណ៍អក្សរក្នុងលិខិតមួយ ។

លិខិតនេះត្រូវផ្ញើផ្ទាល់ទៅ គបទ ដែលបញ្ជាក់ថាបានទទួលលិខិតនេះហើយ ។

ការជម្ទាស់ទៅនឹងការពិនិត្យមើលណាមួយរបស់ គបទ ត្រូវចាត់ទុកថាការបន្ថោះអាសន្នប៉ុណ្ណោះ ។ គបទ ត្រូវរៀបចំការពិនិត្យមើលជាថ្មីជាបន្ទាន់ ហើយអាជ្ញាធរពាក់ព័ន្ធត្រូវទទួលយកការពិនិត្យមើលដែលគ្រោងជាថ្មីនេះ។

## មាត្រា១៧: វិធានការណ៍ដែលត្រូវចាត់ក្រោយការពិនិត្យមើល

ក្រោយពីការពិនិត្យណាមួយភ្លាម គបទ ត្រូវជូនពត៌មានដោយផ្ទាល់មាត់ដល់អាជ្ញាធរមានសមត្ថកិច្ច អំពីការរកឃើញនិងអនុសាសន៍របស់ខ្លួនសម្រាប់ការធ្វើការកែលំអនៅក្នុងទីកន្លែងដែលមានការដកហូតសេរីភាព ។ ការជូនពត៌មានដោយផ្ទាល់មាត់នេះមានគោលបំណងធានាឲយមានការផ្តួចផ្តើមកិច្ចសន្ទនាស្ថាបនាជាមួយអាជ្ញាធរមានសមត្ថកិច្ច ។ គបទ ត្រូវសរសេររបាយការណ៍អំពីការរកឃើញរបស់ជូនទៅអាជ្ញាធរមានសមត្ថកិច្ច យ៉ាងយូរណាស់មួយខែក្រោយការពិនិត្យមើល ។

ក្រោយការពិនិត្យមើល បើសិនបានដឹងថាមានអំពើទារុណកម្មនិងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលមានការដកហូតសេរីភាព គបទ ត្រូវជូនពត៌មានទៅប្រធានទីកន្លែងពាក់ព័ន្ធនោះភ្លាម ហើយដាក់របាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ដែរ ។

នៅពេលដែលសិទ្ធិរបស់ជនដែលត្រូវបានដកហូតសេរីភាពណាម្នាក់ ត្រូវបានរំលោភ ឬសន្តិសុខឬសុខភាពជននោះត្រូវប្រឈមគ្រោះថ្នាក់ គបទ ត្រូវទាមទារប្រធានទីកន្លែងពាក់ព័ន្ធឲយចាត់វិធានការណ៍ជាបន្ទាន់ ។ វិធានការណ៍ទាំងនេះរួមមាន តែមិនកម្រិតត្រឹម ការព្យាបាលជម្ងឺ ជំនួយប្រឹក្សា ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស និងការផ្លាស់ជននោះឲយទៅនៅទីកន្លែងដែលមានការដកហូតសេរីភាពណាមួយផ្សេងទៀត ។

បើសិនមានមូលហេតុត្រឹមត្រូវដែលនាំឲយសង្ស័យថាអំពើឧក្រិដ្ឋណាមួយត្រូវបានប្រព្រឹត្ត គបទ ត្រូវរៀបចំរបាយការណ៍មួយ ដោយមានពត៌មានពាក់ព័ន្ធទាំងអស់ ហើយបញ្ជូនរបាយការណ៍នោះទៅព្រះរាជអាជ្ញាដែលមានដែនសមត្ថកិច្ចលើតំបន់ដែលមានទីកន្លែងដែលមានការដកហូតសេរីភាពនោះ ។

ក្នុងរយៈពេលបីខែក្រោយពីបានទទួលរបាយការណ៍ស្តីអំពីការសង្កេតឃើញនិងអនុសាសន៍ពី គបទ ប្រធានទីកន្លែងដែលមានការដកហូតសេរីភាព ត្រូវជូនពត៌មានទៅ គបទ អំពីវិធានការណ៍ដែលខ្លួនបានចាត់ដើម្បីកែលំអស្ថានភាពជនដែលត្រូវបានដកហូតសេរីភាព ។ បើមិនបានទទួលពត៌មាននោះទេ គបទ ត្រូវសុំក្រសួងពាក់ព័ន្ធឲយចាត់វិធានការណ៍ ។ ក្នុងារយៈពេលមួយខែ ក្រសួងពាក់ព័ន្ធត្រូវជូនពត៌មានទៅ គបទ វិញអំពីវិធានការណ៍ដែលខ្លួនបានចាត់ ។

ប្រធានទីកន្លែងពាក់ព័ន្ធ ឬក្រសួងពាក់ព័ន្ធ ត្រូវជួបជុំសន្ទនាគ្នាដើម្បីរកវិធានការណ៍កែលំអ បើសិនជាប្រធាននោះ ឬក្រសួងនោះមិនទាន់បានចាត់វិធានការណ៍ក្នុងរយៈពេលកំណត់ ឬវិធានការណ៍ដែលបានចាត់មិនទាន់បានជាទីពេញចិត្តនៅឡើយ ។ គបទ ត្រូវកត់សំគាល់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួននូវការនៅស្ងៀមមិនចាត់ការ ឬការបដិសេធន៍មិនព្រមធ្វើការសន្ទនាគ្នាពីសំណាក់ប្រធានទីកន្លែងពាក់ព័ន្ធ នឹង-ឬ ក្រសួងពាក់ព័ន្ធ ។

ក្នុងរយៈពេលមួយខែក្រោយពីបានទទួលរបាយការណ៍ពី គបទ ព្រះរាជអាជ្ញាត្រូវជូនពត៌មានទៅ គបទ អំពីបណ្តឹងអាជ្ញាដែលខ្លួនបានធ្វើ ។ គបទ កត់សំគាល់ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន នូវការនៅស្ងៀមមិនបានធ្វើបណ្តឹងអាជ្ញា ។

## មាត្រា ១៨: របាយការណ៍

ក្នុងរយៈពេលបីខែបន្ទាប់ពីដាច់ឆ្នាំហិរញ្ញវត្ថុម្តងៗ គបទ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនដាក់ថ្វាយព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី រដ្ឋសភា ព្រឹទ្ធសភា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ អ្នកដឹកនាំប្រទេស និងស្ថាប័នទាំងអស់នេះអាចធ្វើអត្ថាធិប្បាយលើរបាយការណ៍ក្នុងរយៈពេលមួយខែក្រោយដែលបានតទទួលរបាយការណ៍នោះ ។ គបទ ត្រូវបញ្ចូលរបាយការណ៍ទាំងនេះទៅក្នុងរបាយការណ៍ ហើយត្រូវទទួលខុសត្រូវក្នុងការបោះពុម្ពនិងផ្សព្វផ្សាយរបាយការណ៍របស់ខ្លួន ។

## មាត្រា ១៩: ទោសបញ្ញត្តិចំពោះការមិនអនុវត្តតាម

គបទ ត្រូវជូនពត៌មានទៅអាជ្ញាធរដែលមានអំណាចដាក់វិន័យ នូវហេតុការណ៍ទាំងអស់ដែលអាចឲយមានវិធានការណ៍ដាក់វិន័យ ឬបណ្តឹងអាជ្ញា ។

ភ្នាក់ងារសាធារណៈដែលខកខានមិនបានធ្វើតាមការសុំរបស់ គបទ ដោយអនុទ្បោមតាមមាត្រា ១៥ វាគ្យខ័ណ្ឌទី២ ឬមិនបានធ្វើតាមបទបញ្ញត្តិនៃមាត្រា១៦ វាគ្យខ័ណ្ឌទី២ នៃច្បាប់នេះ ឬក៏ធ្វើការលូកដៃចូលដែលនាំឲយប៉ះពាល់ដល់ឯករាជភាពឬសកកម្មភាពរបស់ គបទ ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ ។ ក្នុងរយៈពេលមួយខែក្រោយពីបានទទួលកាសសុំ ឬការតវ៉ាអំពីការមិនធ្វើតាមឬការលូកដៃចូល អាជ្ញាធរពាក់ព័ន្ធដែលមានអំ

ណាចដាក់វិន័យ ត្រូវជូនពត៌មានទៅ គបទ អំពីវិធានការណ៍ដែលខ្លួនបានចាត់ទៅលើភ្នាក់ងារនោះ ។ ភ្នាក់ងារដដែលនោះអាចត្រូវចោទប្រកាន់ព្រហ្មទណ្ឌពីបទធ្វេសសប្រហែសព្រហ្មទណ្ឌ បើសិនអសកម្មភាពរបស់ភ្នាក់ងារនោះបាននាំមកនូវរបួសឬការស្លាប់ជនដែលត្រូវបានដកហូតសេរីភាព ។ ភ្នាក់ងារសាធារណៈណាដែលបានផ្តល់ពត៌មានមិនពិតដោយចេតនា ឬដែលបានណែនាំសាក្សីឲយធ្វើបែបនេះដែរ ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យនិងការចោទប្រកាន់ព្រហ្មទណ្ឌពីបទឆបោក ។

ភ្នាក់ងារសាធារណៈក្នុងមាត្រានេះនិងជាបន្តបន្ទាប់នៅក្នុងច្បាប់នេះក៏សំដៅដល់ភ្នាក់ងារបម្រើការ ឬទទួលខុសត្រូវចំពោះទីកន្លែងឯកជនដែលមានការដកហូតសេរីភាពដូដែលមានចែងក្នុងមាត្រ៣នៃច្បាប់នេះ ។

## មាត្រា ២០: ការការពារជនដែលសហការជាមួយ គបទ

គ្មានអាជ្ញាធរណា ឬមន្ត្រីរាជការណា អាចបញ្ជាឲយមានការដាក់ទណ្ឌកម្ម ដាក់ទណ្ឌកម្មដោយខ្លួនឯង អនុញ្ញាតឲយដាក់ទណ្ឌកម្ម ឬអត់ឱនដល់ការដាក់ទណ្ឌកម្ម ទៅលើជនណាដែលផ្តល់ពត៌មានជូន គបទ ទោះជាពត៌មាននោះពិតក្តីឬខុសក្តី ហើយជនបែបនេះមិនត្រូវរងការប្រកាន់មិនរាប់រកបែបណាមួយឡើយ ។

## មាត្រា ២១: ការពិនិត្យរបស់អាជ្ញាធរនិងអង្គការឯទៀត

ការបង្កើតនិងការប្រព្រឹត្តទៅរបស់ គបទ នេះ មិនត្រូវមានអ្វីធ្វើឲយប៉ះពាល់ដោយប្រការណាមួយដល់ការពិនិត្យមើលទីកន្លែងដដែល ដែលធ្វើឡើងដោយអាជ្ញាធរ អង្គការជាតិ ឬអន្តរជាតិ និងបុគ្គលឯទៀតឡើយ ។

# ជំពូកទី៥
# នីតិវិធីបណ្តឹងតវ៉ា

## មាត្រា ២២: បណ្តឹងតវ៉ាអំពីទារុណកម្ម

ជនណាក៏ដោយដែលអះអាងថាជាជនរងគ្រោះពីអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ប្រព្រឹត្តដោយភ្នាក់ងារសាធារណៈណាម្នាក់ ត្រូវមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅ គបទ ។ ជនរងគ្រោះអាចប្តឹងតវ៉ាទៅ គបទ ឬមួយដោយផ្ទាល់នៅទីកន្លែងដែលមានការដកហូតសេរីភាព នៅពេលដែល គបទ ធ្វើការពិនិត្យមើលឬនៅទីស្នាក់ការ គបទ ឬមួយតាមរយៈមេធាវីឬសមាជិកគ្រួសារនាមួយរបស់ខ្លួន ។

អង្គការក្រៅរដ្ឋាភិបាលមានសិទ្ធិជូនពត៌មានទៅ គបទ អំពីអំពើទារុណកម្មនិងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលខ្លួនអាចបានសង្កេតឃើញនៅពេលដែលបានទៅធ្វើការពិនិត្យមើលនៅទីកន្លែងដែលដកហូតសេរីភាព ។

ក្នុងរយៈពេលពីរអាទិត្យក្រោយពីបានទទួលបណ្តឹងតវ៉ា គបទ ត្រូវជូនដំណឹងថាបានទទួលបណ្តឹងតវ៉ានេះ ព្រមទាំងដំណឹងអំពីផែនការធ្វើការពីនិត្យមើលទីកន្លែងនិងជនរងគ្រោះពាក់ព័ន្ធ ។ គបទ ត្រូវជូនពត៌មានជាបន្តអំពីការជឿនលឿននៃការងាររបស់ខ្លួន និវិធានការណ៍ដែលខ្លួនបានចាត់ ។

# ជំពូកទី ៦
# បទបញ្ញតិបញ្ចប់

## មាត្រា ២៣: ការពិនិត្យសារឡើងវិញ

រដ្ឋសភាត្រូវពិនិត្យច្បាប់នេះសារឡើងវិញបីឆ្នាំក្រោយដែលច្បាប់នេះចូលជាធរមាន ដើម្បីវាយតម្លៃការអនុវត្ត និងបង្កើនប្រសិទ្ធភាពរបស់គបទ ។ បន្ទាប់ពីនេះ រដ្ឋសភាត្រូវធ្វើការពិនិត្យច្បាប់នេះសារឡើងវិញនេះប្រាំឆ្នាំម្តងៗ ។ រដ្ឋសភាត្រូវផ្សព្វផ្សាយរបាយការណ៍អំពីការពិនិត្យសារឡើងវិញជាសាធារណៈ ។

មាត្រា ២៩: នរាករណ៍នៃច្បាប់និងបទបញ្ញត្តិផ្ទុយ

ច្បាប់និងបទបញ្ញត្តិណាដែលផ្ទុយពីបទបញ្ញត្តិនៃច្បាប់នេះត្រូវទុកជានារាករណ៍ ៕